ក្រសួងអប់រំ យុវជន និងកីឡា

កាយរឹទ្ធិជាតិកម្ពុជា

# ក្រុមភ្លេងកាយរឹទ្ធិ

# Scout Marching Band



Messengers of Peace

# ខ្ញុំជាកាយរឹទ្ធិ ខ្ញុំជាអ្នកនាំសារសន្តិភាព!
# សន្តិភាពចាប់ផ្ដើមពីខ្ញុំ!




ការប្រកួត
រូបថត កាយរឹទ្ធិថ្នាក់ជាតិ

# កាយរឹទ្ធិជាតិកម្ពុជា
# រួមគ្នាការពារសន្តិភាព



# មាតិកា


## ១ សារតារក្រុមភ្លេងកាយរឹទ្ធិ

- ក្រុមភ្លេងកាយរឹទ្ធិពិភពលោក
- ក្រុមភ្លេងកាយរឹទ្ធិជាតិកម្ពុជា

## ២ ការរៀបចំក្រុមភ្លេងកាយរឹទ្ធិ

- គោលបំណង
- លទ្ធផលរំពឹងទុក និងអត្ថប្រយោជន៍
- ឧបករណ៍ភ្លេងកាយរឹទ្ធិ

## ៣ ការប្រកួតក្រុមភ្លេងកាយរឹទ្ធិថ្នាក់ជាតិ

- សារតារការប្រកួតក្រុមភ្លេងកាយរឹទ្ធិថ្នាក់ជាតិ
- គោលបំណង និងលទ្ធផលរំពឹងទុក
- ការប្រកួតក្រុមភ្លេងកាយរឹទ្ធិថ្នាក់ជាតិលើកទី១
- ការជ្រើសរើស និងលក្ខខណ្ឌចូលរួម
- ការប្រកួតក្រុមភ្លេងកាយរឹទ្ធិថ្នាក់ជាតិលើកទី២

## ៤ ការប្រកួតក្រុមភ្លេងកាយរឹទ្ធិថ្នាក់ជាតិលើកទី៣

- ប្រធានបទ និងបណ្ណសញ្ញា
- ព័ត៌មានក្រុមភ្លេងកាយរឹទ្ធិ ១៣ រាជធានី ខេត្ត



## ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

និងជាប្រធានកាយរឹទ្ធិជាតិកម្ពុជា

# សារលិខិត

ក្នុងនាមកាយរឹទ្ធិជាតិកម្ពុជា ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្ដៅចំពោះប្រតិភូក្រុមភ្លេងកាយរឹទ្ធិរាជធានី ខេត្ត ថ្នាក់ដឹកនាំក្រសួងស្ថាប័ន សិស្សានុសិស្ស វិស័យឯកជន និងអង្គការដៃគូទាំងអស់ នៅក្នុងព្រឹត្តិការណ៍ប្រកួតក្រុមភ្លេងកាយរឹទ្ធិថ្នាក់ជាតិលើកទី៣ ក្រោមប្រធានបទ "ភ្លេងកាយរឹទ្ធិ ដើម្បីសន្តិភាពនិងការអភិវឌ្ឍ"។ ឆ្លើយតបតាមអនុសាសន៍ដឹកនាំប្រកបដោយគតិបណ្ឌិតរបស់**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និង**លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត** ជាគុរុគណ **នៃកាយរឹទ្ធិជាតិកម្ពុជា** ក្រសួងអប់រំ យុវជន និងកីឡា និងកាយរឹទ្ធិជាតិកម្ពុជា បានសហការរៀបចំការប្រកួតក្រុមភ្លេងកាយរឹទ្ធិថ្នាក់ជាតិ ដើម្បីគាំទ្រដល់ការងារអប់រំ និងសកម្មភាពសិក្សាក្រៅម៉ោងបន្ថែមនៅតាមគ្រឹះស្ថានសិក្សានានា។

ក្នុងបរិបទពិភពលោក ដែលកំពុងប្រឈមទៅនឹងការប្រែប្រួលសណ្ដាប់ធ្នាប់ដ៏ស្មុគស្មាញ ប្រជាជនកម្ពុជាមាន បំណងប្រាថ្នារស់នៅក្រោមដំបូលនៃសន្តិភាពនិងការអភិវឌ្ឍលើគ្រប់វិស័យ។ ការប្រកួតក្រុមភ្លេងកាយរឹទ្ធិបានក្លាយជាសំឡេងបន្លឺឡើង ដើម្បីបង្ហាញដល់សហគមន៍អន្តរជាតិ ឱ្យបានឃើញអំពីសាមគ្គីភាព ការគោរពវិន័យ សេចក្ដីថ្លៃថ្នូរ និងឆន្ទៈរបស់យុវជនកម្ពុជាគ្រប់រូបក្នុងការរួមរស់ជាមួយប្រទេសជិតខាង ប្រកបដោយភាពសុខដុមរមនា និងសន្តិភាព។

លោក Robert Stephenson Smyth Baden-Powell ស្ថាបនិកចលនាកាយរឹទ្ធិពិភពលោក បានលើកឡើងថា៖ "Try and leave this world a little better than you found it." មានន័យថា៖ "សូមព្យាយាមធ្វើឱ្យពិភពលោកនេះឱ្យកាន់តែល្អ ប្រសើរជាង អំឡុងពេលដែលអ្នកមើលឃើញវា"។ ទស្សនៈនេះបានបង្ហាញពីគោលបំណងនៃការអប់រំកាយរឹទ្ធិកម្ម ដែលលើសពី ការបណ្ដុះបណ្ដាលចំណេះដឹងដល់យុវជន ពោលគឺការអប់រំកាយរឹទ្ធិកម្មពិតជា បានបណ្ដុះនូវស្មារតីយុវជនប្រកបដោយ ទំនួលខុសត្រូវចំពោះសង្គម និងក្លាយជាពលរដ្ឋសកម្មនៅសហគមន៍រស់នៅរបស់ខ្លួន។

ការបង្កើតក្រុមភ្លេងកាយរឹទ្ធិ បានដើរតួនាទីយ៉ាងសំខាន់ដល់ការគាំទ្រវិស័យអប់រំ និងសកម្មភាពសិក្សា នៅតាមគ្រឹះស្ថានសិក្សា។ក្រុមភ្លេងកាយរឹទ្ធិបានជួយបង្កើតបរិយាកាសសិក្សាប្រកបដោយវិន័យសកម្មភាពរស់រវើក និងការច្នៃប្រឌិត។ក្រុមភ្លេងកាយរឹទ្ធិមានអត្ថន័យលើសពីសិល្បៈតន្ត្រីដែលជាវិធីសាស្ត្រអប់រំមួយដ៏មានប្រសិទ្ធភាពក្នុងការអភិវឌ្ឍបុគ្គលិកលក្ខណៈ ការងារជាក្រុម ការគោរពវិន័យ ការទទួលខុសត្រូវ និងភាពជាអ្នកដឹកនាំ។

ដើម្បីជំរុញការរៀបចំក្រុមភ្លេងកាយរឹទ្ធិឱ្យមានប្រសិទ្ធភាព និងចីរភាព ខ្ញុំសូមអំពាវនាវដល់កាយរឹទ្ធិរាជធានីខេត្ត វិស័យឯកជន អង្គការដៃគូ និងអ្នកពាក់ព័ន្ធ ចូលរួមគាំទ្រផ្នែកហិរញ្ញវត្ថុ ឧបករណ៍ភ្លេង និងបច្ចេកទេសដើម្បីអភិវឌ្ឍក្រុមភ្លេងកាយរឹទ្ធិរាជធានី ខេត្ត ឱ្យកាន់តែមានគុណភាព និងសមត្ថភាពប្រកួតប្រជែងនៅកម្រិតជាតិ និងអន្តរជាតិ។

ជាចុងក្រោយ ខ្ញុំសូមអបអរសាទរ និងជូនពរដល់ការប្រកួតក្រុមភ្លេងកាយរឹទ្ធិថ្នាក់ជាតិលើកទី៣ ឱ្យប្រព្រឹត្តទៅដោយជោគជ័យ និងទទួលបានលទ្ធផលល្អប្រសើរ។ សូមជូនពរដល់ប្រតិភូក្រុមភ្លេងកាយរឹទ្ធិរាជធានី ខេត្តទាំងអស់ទទួលបានជោគជ័យក្នុងការបង្ហាញសមត្ថភាព និងបន្តរួមចំណែកក្នុងការអភិវឌ្ឍមាតុភូមិកម្ពុជា។

## ព្រឹទ្ធាចារ្យគរុគណ នៃកាយរឹទ្ធិជាតិកម្ពុជា





**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា**
**និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន**

## គរុគណ នៃកាយរឹទ្ធិជាតិកម្ពុជា



**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**
**និងលោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត**

# ១ សារតារក្រុមភ្លេងកាយរឹទ្ធិ

## ១.១ ក្រុមភ្លេងកាយរឹទ្ធិពិភពលោក

ប្រវត្តិនៃការបង្កើតក្រុមភ្លេងកាយរឹទ្ធិមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងការអប់រំកាយរឹទ្ធិកម្ម។ ក្រុមភ្លេងកាយរឹទ្ធិ បានបង្កើតឡើងសម្រាប់ការអប់រំវិន័យ សីលធម៌ ឥរិយាបថ ការងារជាក្រុម ស្មារតីស្នេហាជាតិ និងការចូលរួមការងារសង្គម និងសហគមន៍។ ចាប់ពីដើមសតវត្សរ៍ទី២០ ក្រុមភ្លេងកាយរឹទ្ធិបានដើរតួនាទី និងចូលរួមយ៉ាងសកម្មនៅក្នុងព្រឹត្តិការណ៍កាយរឹទ្ធិនៅជុំវិញពិភពលោក។





ចលនាកាយរឹទ្ធិពិភពលោក ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩០៧ ដោយលោក Robert Stephenson Smyth Baden-Powell បានរីករាលដាលយ៉ាងឆាប់រហ័សពាសពេញទ្វីបអឺរ៉ុបនិងជុំវិញពិភពលោក។ លោក Baden-Powell បានបង្កើតក្រុមភ្លេងកាយរឹទ្ធិដើម្បីដើរបង្ហាញនៅក្នុងក្បួនព្យុហយាត្រាជាលើកដំបូងនៅក្នុងពិធីបើកការបោះជំរំកាយរឹទ្ធិជំទង់ពិភពលោកលើកទី១ (1st World Scout Jamboree) ក្នុងឆ្នាំ១៩២០ នៅទីក្រុងអូឡាំពីយ៉ា ចក្រភពអង់គ្លេស។

ចាប់តាំងពីពេលនោះមក បណ្ដាប្រទេសនៅក្នុងទ្វីបអឺរ៉ុបនិងអាមេរិក បានបង្កើតក្រុមភ្លេងកាយរឹទ្ធិដោយដាក់បញ្ចូលកម្មវិធីហ្វឹកហាត់ភ្លេងកាយរឹទ្ធិទៅក្នុងក្របខណ្ឌកម្មវិធីយុវជន (Youth Program Framework) នៃការអប់រំកាយរឹទ្ធិកម្ម។ ឧបករណ៍សំខាន់ៗក្រុមភ្លេងកាយរឹទ្ធិមាន ០៣ប្រភេទ៖ ត្រែ(Bugles) ស្គរ (Drums) និងកញ្ចែ(Whistles) ដើម្បីប្រើជាសញ្ញាសន្ទត (Scouting's Signal) នៅក្នុងពេលបោះជំរំកាយរឹទ្ធិថ្មើរព្រៃ និងសកម្មភាពនៅទីវាល។ ក្រោយមកបណ្ដាប្រទេសជឿនលឿន បានអភិវឌ្ឍក្រុមភ្លេងកាយរឹទ្ធិដោយបន្ថែមឧបករណ៍ភ្លេងកាន់តែសម្បូរបែប និងប្រែក្លាយទៅជាក្រុមភ្លេងកាយរឹទ្ធិ សម្រាប់ចូលរួមក្នុងដំណើរក្បួនព្យុហយាត្រា ពិធីបុណ្យជាតិ និងព្រឹត្តិការណ៍សង្គមផ្សេងៗ។

# ១.២ ក្រុមភ្លេងកាយរឹទ្ធិជាតិកម្ពុជា



ចលនាកាយរឹទ្ធិជាតិកម្ពុជា បានចាប់បដិសន្ធិឡើងនៅក្នុងឆ្នាំ១៩៣៤ នៅក្នុងសម័យកាលព្រះរាជាណាចក្រកម្ពុជាស្ថិតក្រោមអាណានិគមបារាំង។ ដោយកត្តាប្រែប្រួលនយោបាយ និងអស្ថិរភាពសង្គម ចលនាកាយរឹទ្ធិជាតិកម្ពុជាមិនបានដំណើរការនោះទេ។ ក្នុងឆ្នាំ២០០០ ចលនាកាយរឹទ្ធិជាតិកម្ពុជាត្រូវបានបង្កើតឡើងវិញបន្ទាប់ពីមានកិច្ចជំនួបរវាងគណៈប្រតិភូរបស់អង្គការពិភពលោកនៃចលនាកាយរឹទ្ធិប្រចាំតំបន់អាស៊ី-ប៉ាស៊ីហ្វិក ជាមួយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ១៩៩៩។

ក្រោមការជួយឧបត្ថម្ភគាំទ្រពី **សម្តេចវិបុលបញ្ញា សុខ អាន** អតីតប្រធានកាយរឹទ្ធិជាតិកម្ពុជានៅក្នុងឆ្នាំ២០០៦ កាយរឹទ្ធិជាតិកម្ពុជា បានបង្កើតក្រុមភ្លេងកាយរឹទ្ធិរាជធានីខេត្តចំនួន ១២ក្រុម៖ ក្រុមភ្លេងកាយរឹទ្ធិជាតិកម្ពុជា ០១ក្រុម នៅក្នុងវិទ្យាល័យវត្តកោះ ក្រុមភ្លេងកាយរឹទ្ធិរាជធានីភ្នំពេញ ០២ក្រុម ខេត្តសៀមរាប ០១ក្រុម ខេត្តតាកែវ ០១ក្រុម ខេត្តកណ្តាល ០១ក្រុម ខេត្តរតនគិរី ០១ក្រុម ខេត្តកំពង់ស្ពឺ ០១ក្រុម ខេត្តបន្ទាយមានជ័យ ០១ក្រុម ខេត្តឧត្តរមានជ័យ ០១ក្រុម និងខេត្តកោះកុង ០១ក្រុម។

ក្រុមភ្លេងកាយរឹទ្ធិជាតិកម្ពុជាបានចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពរបស់រាជរដ្ឋាភិបាល រដ្ឋបាលរាជធានីខេត្ត និងសកម្មភាពសង្គមនានា។






# ២

# ការរៀបចំក្រុមភ្លេងកាយរឹទ្ធិ

## ២.១ គោលបំណង

ក្រុមភ្លេងកាយរឹទ្ធិ រៀបចំឡើងក្នុងគោលបំណងអភិវឌ្ឍកុមារនិងយុវជន ខាងផ្លូវកាយ ផ្លូវបញ្ញា ផ្លូវអារម្មណ៍ ផ្លូវសង្គម និងផ្លូវចិត្ត ដើម្បីឱ្យក្លាយជាពលរដ្ឋសកល ពលរដ្ឋសកម្ម និងមានទំនួលខុសត្រូវខ្ពស់នៅក្នុងសហគមន៍រស់នៅរបស់ខ្លួន។ ក្រុមភ្លេងកាយរឹទ្ធិ បានបណ្ដុះស្មារតីកាយរឹទ្ធិ និងការអប់រំកាយរឹទ្ធិកម្មដល់កុមារនិងយុវជន តាមរយៈសិល្បៈប្រគំតូរ្យតន្ត្រី ការសម្ដែងសមត្ថភាពជាក្រុមបែបរីករាយរស់រវើក លំហាត់របៀប និងការបញ្ជាសណ្ដាប់ធ្នាប់កាយរឹទ្ធិ។



## ២.២ លទ្ធផលរំពឹងទុកនិងអត្ថប្រយោជន៍

ការបង្កើតក្រុមភ្លេងកាយរឹទ្ធិពិតជាបានឆ្លើយតបយ៉ាងវិជ្ជមាន តបតាមផែនការយុទ្ធសាស្ត្រវិស័យអប់រំដែលបានកំណត់យកយុទ្ធសាស្ត្រអាទិភាព "ផ្ដល់ឱកាសដល់យុវជនគ្រប់រូបទទួលបានការអប់រំនិងការបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈប្រកបដោយគុណធម៌ និងសមធម៌ ព្រមទាំងការលើកទឹកចិត្តយុវជន ឱ្យមានគំនិត ផ្ដួចផ្ដើម គំនិតច្នៃប្រឌិត គំនិតបង្កើតថ្មី និងស្មារតីសហគ្រិនភាព"។

ការបង្កើតក្រុមភ្លេងកាយរឹទ្ធិផលិតបានធនធានយុវជនដែលមានជំនាញតូរ្យតន្ត្រីជាក់លាក់ មានចរិយាសម្បទាដែលជាតម្រូវការចាំបាច់សម្រាប់បំណិនសតវត្សរ៍ទី២១ និងមានស្មារតីស្នេហាជាតិដ៏រឹងមាំ។





## ២.៣ ឧបករណ៍ភ្លេងកាយរឹទ្ធិ

ឧបករណ៍ភ្លេង ១៣ប្រភេទ និងសមាជិក ៣១នាក់



១. ដំបងបញ្ជាភ្លេង ០១គ្រឿង



២. ខ្លុយក្លារីណែត ០២គ្រឿង



៣. ត្រុំប៉ោនតេណ័រ ០២គ្រឿង



៤. ត្រុំប៉ែត ០៤គ្រឿង



៥. ហ៊្សាក់សូហ្វូនតេណ័រ ០២គ្រឿង



៦. ហ៊្សាក់សូហ្វូនអាលតូ ០២គ្រឿង



៧. ទូបា ០១គ្រឿង



៨. រនាតដែក ០២គ្រឿង



៩. ម៉ូនីកាឃីប៊ិត ០៨គ្រឿង



១០. ឆាប ០២គ្រឿង



១១. ស្គរទោល ០២គ្រឿង



១២. ស្គរភ្លោះបី ០២គ្រឿង



១៣. ស្គរធំ ០១គ្រឿង

# ៣

# ការប្រកួតក្រុមភ្លេងកាយរឹទ្ធិថ្នាក់ជាតិ

## ៣.១ សារតារការប្រកួតក្រុមភ្លេងកាយរឹទ្ធិថ្នាក់ជាតិ







ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** ឧបនាយក-រដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងជាប្រធានកាយរឹទ្ធិជាតិកម្ពុជា បានផ្តួចផ្តើមគំនិត និងផ្តល់អនុសាសន៍ដល់នាយកដ្ឋានសហប្រតិបត្តិការកាយរឹទ្ធិ រៀបចំការប្រកួតក្រុមភ្លេងកាយរឹទ្ធិថ្នាក់ជាតិ។ នៅក្នុងឆ្នាំ២០២៤ នាយកដ្ឋានសហប្រតិបត្តិការកាយរឹទ្ធិបានដាក់បញ្ចូលការប្រកួតក្រុមភ្លេងកាយរឹទ្ធិថ្នាក់ជាតិទៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំ។

ការប្រកួតក្រុមភ្លេងកាយរឹទ្ធិថ្នាក់ជាតិលើកទី១ក្រោមប្រធានបទ "ភ្លេងក្នុងសន្តិភាព" ថ្ងៃទី២-៣ ខែឧសភា ឆ្នាំ២០២៤ និងលើកទី២ ក្រោមប្រធានបទ "ភ្លេងកាយរឹទ្ធិ ដើម្បីមហាបវរិបុលភាព" ថ្ងៃទី២-៣ ខែមិថុនា ឆ្នាំ២០២៥ នៅពហុកីឡដ្ឋានជាតិអូឡាំពិក។

## ៣.២ គោលបំណងនិងលទ្ធផលរំពឹងទុក





ការប្រកួតក្រុមភ្លេងកាយរឹទ្ធិថ្នាក់ជាតិ រៀបចំឡើងក្នុងគោលបំណងអភិវឌ្ឍកុមារនិងយុវជនខាងផ្លូវកាយ ផ្លូវបញ្ញា ផ្លូវអារម្មណ៍ ផ្លូវសង្គម និងផ្លូវចិត្តដើម្បីឱ្យក្លាយជាពលរដ្ឋល្អ ពលរដ្ឋសកម្ម និងមានទំនួលខុសត្រូវខ្ពស់ ព្រមទាំងជាសមាជិកសកម្មក្នុងការរក្សាសន្តិភាពនៅក្នុងសហគមន៍រស់នៅរបស់ខ្លួន។ព្រឹត្តិការណ៍នេះបានបណ្តុះស្មារតីកាយរឹទ្ធិដល់កុមារនិងយុវជន តាមរយៈសិល្បៈប្រគំតន្ត្រីជាក្រុមការសម្តែងបែបរីករាយរស់រវើកលំហាត់របៀបកាយរឹទ្ធិ និងការបញ្ជាសណ្តាប់ធ្នាប់ ព្រមទាំងបង្ហាញសកម្មភាពរបស់កាយរឹទ្ធិជាតិកម្ពុជាលើឆាកជាតិ និងអន្តរជាតិ។

## ៣.៣ បណ្ណសញ្ញា និងប្រធានបទ

### ១. ការប្រកួតក្រុមភ្លេងកាយរឹទ្ធិថ្នាក់ជាតិលើកទី១

កាលបរិច្ឆេទ៖ ថ្ងៃទី២ ដល់ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២៤

ប្រធានបទ៖ **ភ្លេងភ្លូនសន្តិភាព**

ក្រុមភ្លេងកាយរឹទ្ធិ៖ ០៨ក្រុម ស្មើនឹង ០៦រាជធានីខេត្ត

ប្រតិភូក្រុមភ្លេងកាយរឹទ្ធិ៖ ៣៣៦នាក់ ស្រី១៥០នាក់ ។

### ២. ការប្រកួតក្រុមភ្លេងកាយរឹទ្ធិថ្នាក់ជាតិលើកទី២

កាលបរិច្ឆេទ៖ ថ្ងៃទី២ ដល់ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២៥

ប្រធានបទ៖ **ភ្លេងកាយរឹទ្ធិ ដើម្បីមហាបវរវិបុលភាព**

ក្រុមភ្លេងកាយរឹទ្ធិ៖ ០៨ក្រុម ស្មើនឹង ០៨រាជធានីខេត្ត

ប្រតិភូក្រុមភ្លេងកាយរឹទ្ធិ៖ ៣៣៦នាក់ ស្រី១៥០នាក់ ។

## ៣.៤ ការជ្រើសរើស និងលក្ខខណ្ឌចូលរួម

ក្រុមភ្លេងកាយរឹទ្ធិរាជធានី ខេត្ត ត្រូវមានលក្ខខណ្ឌ ដូចជា៖

- កាយរឹទ្ធិរាជធានី ខេត្ត ត្រូវជ្រើសរើសក្រុមភ្លេងកាយរឹទ្ធិ ០១ក្រុម និងដាក់ពាក្យមកនាយកដ្ឋានសហប្រតិបត្តិការកាយរឹទ្ធិ
- សមាសភាពក្រុមភ្លេងកាយរឹទ្ធិរាជធានីខេត្ត៖ អ្នកបញ្ជាភ្លេង ០១នាក់ សមាជិកកាន់ឧបករណ៍ភ្លេង ៣០នាក់ អ្នកសម្ដែង មិនលើសពី ១០នាក់ និងគ្រូដឹកនាំ ០២នាក់
- ជាសមាជិកកាយរឹទ្ធិជាតិកម្ពុជា និងចន្លោះអាយុចាប់ពី០៩ឆ្នាំ ទៅដល់ ២៦ឆ្នាំ
- ប្រតិភូត្រូវមានសុខភាពល្អ បំណិនច្នៃប្រឌិត ស្មារតីធ្វើការងារជាក្រុម និងមានឆន្ទៈចូលរួមគ្រប់កាលៈទេសៈ។





## ៣.៥ ជ័យលាភីការប្រកួតក្រុមភ្លេងកាយរឹទ្ធិថ្នាក់ជាតិ

### ការប្រកួតក្រុមភ្លេងកាយរឹទ្ធិថ្នាក់ជាតិលើកទី១ ឆ្នាំ២០២៤




**ជ័យលាភីលេខ ១**

ក្រុមភ្លេងកាយរឹទ្ធិរាជធានីភ្នំពេញ
វិទ្យាល័យបាក់ទូក







**ជ័យលាភីលេខ ២**

ក្រុមភ្លេងកាយរឹទ្ធិរាជធានីភ្នំពេញ
វិទ្យាល័យ ហ៊ុនសែន ប៊ុនរ៉ានី វត្តភ្នំ







**ជ័យលាភីលេខ ៣**

ក្រុមភ្លេងកាយរឹទ្ធិខេត្តសៀមរាប



### ការប្រកួតក្រុមភ្លេងកាយរឹទ្ធិថ្នាក់ជាតិលើកទី២ ឆ្នាំ២០២៥



**ជ័យលាភីលេខ ១**

ក្រុមភ្លេងកាយរឹទ្ធិខេត្តឧត្តរមានជ័យ






**ជ័យលាភីលេខ ២**

ក្រុមភ្លេងកាយរឹទ្ធិខេត្តកោះកុង






**ជ័យលាភីលេខ ៣**

ក្រុមភ្លេងកាយរឹទ្ធិខេត្តកណ្តាល



# ៤

# ការប្រកួតក្រុមភ្លេងកាយរឹទ្ធិថ្នាក់ជាតិលើកទី៣

## ៤.១ ប្រធានបទ និងបណ្ណាសញ្ញា

### ១. ប្រធានបទ៖

ភ្លេងកាយរឹទ្ធិ ដើម្បីសន្តិភាពនិងការអភិវឌ្ឍ ( Scout Marching Band for Peace and Development ) ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងជាប្រធានកាយរឹទ្ធិជាតិកម្ពុជា បានកំណត់យកប្រធានបទឆ្នាំ២០២៦ ឆ្លើយតបតាមសភាពការណ៍ឈ្លានពានរបស់យោធាថៃលើអធិបតេយ្យភាពកម្ពុជា។ ប្រជាជនកម្ពុជាគ្រប់រូបត្រូវការសន្តិភាព និងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិ។

### ២. បណ្ណាសញ្ញា៖

⚜ **រចនាបថ៖** ទម្រង់រូបសត្វព្រាបហើរត្រដាងស្លាបពាំស្លឹកអូលីវ និមិត្តសញ្ញាកាយរឹទ្ធិជាតិកម្ពុជា និងអក្សរភ្លេងកាយរឹទ្ធិតំណាងឱ្យការអប់រំកាយរឹទ្ធិកម្ម និងវិមានពណ៌ស្វាយជាអត្តសញ្ញាណចលនាកាយរឹទ្ធិពិភពលោកនិងការប្តេជ្ញាចិត្តចូលរួមបង្កើតពិភពលោក មួយដ៏ស្រស់ត្រកាល និងសន្តិភាព។

⚜ **វិមានឈ្នះឈ្នះ៖** រំលឹកស្មារតីដល់សមាជិកកាយរឹទ្ធិជាតិកម្ពុជាគ្រប់រូបត្រូវចងចាំជានិច្ចនូវគុណូបការៈនិងពលិកម្មដ៏ធំធេងរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុនសែន** ស្ថាបនិកឯកនយោបាយឈ្នះឈ្នះ ក្នុងកិច្ចខិតខំស្វែងរកសន្តិភាពជូនប្រជាជនកម្ពុជា និងមានការអភិវឌ្ឍលើគ្រប់វិស័យមកដល់បច្ចុប្បន្ន។



## ៤.២ ប្រតិភូក្រុមក្លេងកាយរឹទ្ធិរាជធានី ខេត្ត

| ល.រ | ក្រុមក្លេងកាយរឹទ្ធិ | គ្រឹះស្ថានសិក្សា |
|---|---|---|
| ១. | ក្រុមក្លេងកាយរឹទ្ធិ ខេត្តឧត្តរមានជ័យ | វិ.តេជោសែន សំរោង វិ.ហ៊ុនសែន ឧត្តរមានជ័យ |
| ២. | ក្រុមក្លេងកាយរឹទ្ធិ ខេត្តប៉ៃលិន | វិទ្យាល័យ ហ៊ុនសែន ក្រុងទេពនិម្មិតប៉ៃលិន |
| ៣. | ក្រុមក្លេងកាយរឹទ្ធិ ខេត្តបាត់ដំបង | ក្រុមក្លេងកាយរឹទ្ធិ អ៊ឹម.ប៊ី.អេស |
| ៤. | ក្រុមក្លេងកាយរឹទ្ធិ ខេត្តស្ទឹងត្រែង | វិទ្យាល័យ ព្រះរាជបូជនីយកិច្ច |
| ៥. | ក្រុមក្លេងកាយរឹទ្ធិ ខេត្តបន្ទាយមានជ័យ | វិទ្យាល័យ ហ៊ុនសែន ខ្លាកូន |
| ៦. | ក្រុមក្លេងកាយរឹទ្ធិ ខេត្តព្រះសីហនុ | វិទ្យាល័យ ហ៊ុនសែន មិត្តភាព |
| ៧. | ក្រុមក្លេងកាយរឹទ្ធិ ខេត្តរតនគិរី | មន្ទីរអប់រំ យុវជន និងកីឡាខេត្តរតនគិរី |
| ៨. | ក្រុមក្លេងកាយរឹទ្ធិ ខេត្តកំពង់ធំ | មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ធំ |
| ៩. | ក្រុមក្លេងកាយរឹទ្ធិ រាជធានីភ្នំពេញ | វិទ្យាល័យ បាក់ទូក |
| ១០. | ក្រុមក្លេងកាយរឹទ្ធិ ខេត្តសៀមរាប | វិទ្យាល័យ ១០ មករា ១៩៧៩ |
| ១១. | ក្រុមក្លេងកាយរឹទ្ធិ ខេត្តកណ្តាល | មជ្ឈមណ្ឌលយុវជនខេត្តកណ្តាល |
| ១២. | ក្រុមក្លេងកាយរឹទ្ធិ ខេត្តកោះកុង | វិទ្យាល័យ ច.ប. តេជោសែនកោះកុង |
| ១៣. | ក្រុមក្លេងកាយរឹទ្ធិ ខេត្តកំពង់ចាម | វិទ្យាល័យ ហ៊ុនសែន ខ្ញៅ |

ព្រឹត្តិការណ៍ប្រកួតក្រុមក្លេងកាយរឹទ្ធិថ្នាក់ជាតិលើកទី៣ មានក្រុមក្លេងកាយរឹទ្ធិរាជធានីខេត្តចុះឈ្មោះចូលរួមប្រកួតចំនួន ១៣ក្រុម ដែលមានចំនួនប្រតិភូកាយរឹទ្ធិ ៥៥៩នាក់។



## ក្រុមភ្លេងកាយរឹទ្ធិ ខេត្តឧត្តរមានជ័យ

### ១ សាវតារ

ក្រុមភ្លេងកាយរឹទ្ធិខេត្តឧត្តរមានជ័យ បានបង្កើតឡើងនៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៩ ក្រោមការជួយឧបត្ថម្ភគាំទ្រពីរដ្ឋបាលខេត្តឧត្តរមានជ័យនិងមន្ទីរអប់រំយុវជននិងកីឡាខេត្តឧត្តរមានជ័យ។ក្រុមភ្លេងកាយរឹទ្ធិនេះ មានសមាសភាពជាកាយរឹទ្ធិជំទង់និងកាយរឹទ្ធិប្អូន ៤៨នាក់ ស្រី ២៩នាក់ មកពីកងឯកភាពវិទ្យាល័យតេជោសែនសំរោងវិទ្យាល័យហ៊ុនសែនឧត្តរមានជ័យនិងសាលាបឋមសិក្សាសំរោង។ ក្រុមភ្លេងកាយរឹទ្ធិខេត្តឧត្តរមានជ័យ បានចូលរួមយ៉ាងសកម្មនៅក្នុងពិធីបុណ្យជាតិ និងព្រឹត្តិការណ៍នានា ដែលរៀបចំដោយរដ្ឋបាលខេត្តឧត្តរមានជ័យ និងមន្ទីរអប់រំ យុវជន និងកីឡាខេត្តឧត្តរមានជ័យ។

### ២ ឈ្មោះនិងសម្រែកក្រុមភ្លេងកាយរឹទ្ធិ

- ឈ្មោះក្រុមភ្លេងកាយរឹទ្ធិខេត្តឧត្តរមានជ័យ៖ "ក្រុមភ្លេងព្យុហយាត្រាកាយរឹទ្ធិខេត្តឧត្តរមានជ័យ"។
- សម្រែកក្រុមភ្លេងកាយរឹទ្ធិ៖ ចាប់ផ្តើមមេក្រុមស្រែកពាក្យ "យក្សអរ" សមាជិកស្រែកបន្ទរពាក្យ "ហ៊ារ" ។ បន្ទាប់មកមេក្រុមស្រែកពាក្យ "ឧត្តរ" សមាជិកស្រែកបន្ទរពាក្យ "មានជ័យ" ចំនួន៣ដង និងបញ្ចប់ដោយការទះដៃស្រុះគ្នាមួយដង ។







# ក្រុមភ្លេងកាយរឹទ្ធិ ខេត្តប៉ៃលិន

## ១ សាវតារ

ក្រុមភ្លេងកាយរឹទ្ធិខេត្តប៉ៃលិន បានបង្កើតឡើងនៅថ្ងៃទី១ ខែមករា ឆ្នាំ២០២៥ ក្រោមការជួយឧបត្ថម្ភគាំទ្រពីរដ្ឋបាលខេត្តប៉ៃលិន និងមន្ទីរអប់រំ យុវជន និងកីឡាខេត្តប៉ៃលិន។ ក្រុមភ្លេងនេះ មានសមាសភាពជាកាយរឹទ្ធិជំទង់និងកាយរឹទ្ធិប្អូន ៥៤នាក់ ស្រី ២៥នាក់ មកពីកងឯកភាពវិទ្យាល័យហ៊ុនសែន ក្រុងទេពនិមិត្ត និងសាលាបឋមសិក្សា រតនសោភ័ណ។ ក្រុមភ្លេងកាយរឹទ្ធិនេះ បានចូលរួមយ៉ាងសកម្មនៅក្នុងពិធីបុណ្យជាតិ និង ព្រឹត្តិការណ៍នានា ដែលរៀបចំដោយរដ្ឋបាលខេត្តប៉ៃលិន និងមន្ទីរអប់រំ យុវជន និងកីឡាខេត្តប៉ៃលិន។ នេះជាលើកដំបូង ក្រុមភ្លេងកាយរឹទ្ធិខេត្តប៉ៃលិនចូលរួមការប្រកួតក្រុមភ្លេងកាយរឹទ្ធិថ្នាក់ជាតិលើកទី៣។

## ២ ឈ្មោះនិងសម្រែកក្រុមភ្លេងកាយរឹទ្ធិ

- ក្រុមភ្លេងកាយរឹទ្ធិខេត្តប៉ៃលិនមានឈ្មោះ៖ "ក្រុមភ្លេងព្យុហយាត្រាកាយរឹទ្ធិ មរតកកូឡា"។
- សម្រែកក្រុមភ្លេងកាយរឹទ្ធិ៖ ចាប់ផ្តើមមេក្រុមស្រែកពាក្យ "មរតកូឡា" សមាជិកស្រែកបន្ទរពាក្យ "ហ៊ែរ"។ បន្ទាប់មកមេក្រុមស្រែកពាក្យ "មរតកកូឡា" សមាជិកស្រែកបន្ទរពាក្យ "ឈ្នះ ឈ្នះ" ចំនួន៣ដង។







## ក្រុមភ្លេងកាយរឹទ្ធិ ខេត្តបាត់ដំបង

### ១ សារតារ

ក្រុមភ្លេងកាយរឹទ្ធិខេត្តបាត់ដំបង បានបង្កើតឡើងនៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២៥ ស្ថិតក្រោមការគ្រប់គ្រង សាលាគុនតេក្វាន់ដូ អ៊ឹម.ប៊ី.អេស. ខេត្តបាត់ដំបង។ ក្រុមភ្លេងកាយរឹទ្ធិនេះ មានសមាជិកជាកាយរឹទ្ធិជំទង់និង កាយរឹទ្ធិប្អូន ៤១នាក់ ស្រី ១៣នាក់ ដឹកនាំដោយលោក ឌួង វុទ្ធី ជាប្រធានសាលាគុនតេក្វាន់ដូ អ៊ឹម.ប៊ី.អេស.។ ក្រុមភ្លេងកាយរឹទ្ធិខេត្តបាត់ដំបង បានចូលរួមយ៉ាងសកម្មនៅក្នុងពិធីបុណ្យជាតិ និងព្រឹត្តិការណ៍នានា រៀបចំដោយរដ្ឋបាលខេត្តបាត់ដំបង និងមន្ទីរអប់រំ យុវជន និងកីឡាខេត្តបាត់ដំបង។

### ២ ឈ្មោះនិងសម្រែកក្រុមភ្លេងកាយរឹទ្ធិ

- ឈ្មោះក្រុមភ្លេងកាយរឹទ្ធិខេត្តបាត់ដំបង៖ "ក្រុមភ្លេងកាយរឹទ្ធិ អ៊ឹម.ប៊ី.អេស."។
- សម្រែកក្រុមភ្លេងកាយរឹទ្ធិ៖ ចាប់ផ្តើមមេក្រុមស្រែកពាក្យ "កាយរឹទ្ធិ" សមាជិកស្រែកបន្ទរពាក្យ "យើងរួមចិត្ត ជាមិត្ត ជាបង ជាប្អូន ធ្វើអំពើល្អ ដើម្បីសន្តិភាព និងការអភិវឌ្ឍ នៅកម្ពុជា"។







# ក្រុមភ្លេងកាយរឹទ្ធិ ខេត្តស្ទឹងត្រែង

## ១ សារតារ

ក្រុមភ្លេងកាយរឹទ្ធិខេត្តស្ទឹងត្រែង បានបង្កើតឡើងនៅឆ្នាំ២០២៥ ក្រោមការជួយឧបត្ថម្ភគាំទ្រពី ឯកឧត្តម **សរ សុពុត្រា** អភិបាល នៃគណៈអភិបាលខេត្តស្ទឹងត្រែង។ ក្រុមភ្លេងកាយរឹទ្ធិនេះ មានសមាជិកកាយរឹទ្ធិ ជំទង់៤១នាក់ស្រី២៧នាក់មកពីកងឯកភាពវិទ្យាល័យព្រះរាជបូជនីយកិច្ច។ក្រុមភ្លេងកាយរឹទ្ធិខេត្តស្ទឹងត្រែង បានចូលរួមយ៉ាងសកម្មក្នុងពិធីបុណ្យជាតិ និងព្រឹត្តិការណ៍នានា រៀបចំដោយរដ្ឋបាលខេត្តស្ទឹងត្រែង និង មន្ទីរអប់រំ យុវជន និងកីឡាខេត្តស្ទឹងត្រែង។

## ២ ឈ្មោះនិងសម្រែកក្រុមភ្លេងកាយរឹទ្ធិ

- ឈ្មោះក្រុមភ្លេងកាយរឹទ្ធិខេត្តស្ទឹងត្រែង៖ "ក្រុមភ្លេងព្យុហយាត្រាកាយរឹទ្ធិខេត្តស្ទឹងត្រែង"។
- សម្រែកក្រុមភ្លេងកាយរឹទ្ធិ៖ ចាប់ផ្ដើមមេក្រុមស្រែកពាក្យ "រ៉ូៗ" សមាជិកស្រែកបន្ទរពាក្យ "ប៊ូម! ស្ទឹងត្រែង អស្ចារ្យ"។







## ក្រុមភ្លេងកាយរឹទ្ធិ ខេត្តបន្ទាយមានជ័យ

### ១ សារតារ

ក្រុមភ្លេងកាយរឹទ្ធិខេត្តបន្ទាយមានជ័យ បានបង្កើតឡើងនៅខែមីនា ឆ្នាំ២០២៤ ក្រោមការជួយឧបត្ថម្ភគាំទ្រពីរដ្ឋបាលខេត្តបន្ទាយមានជ័យ និងមន្ទីរអប់រំ យុវជន និងកីឡាខេត្តបន្ទាយមានជ័យ។ ក្រុមភ្លេងកាយរឹទ្ធិនេះ មានសមាសភាពជាកាយរឹទ្ធិជំទង់ ៣០នាក់ ស្រី ១៨នាក់ មកពីកងឯកភាពវិទ្យាល័យ ហ៊ុនសែន ខ្លាកូន។ ក្រុមភ្លេងកាយរឹទ្ធិខេត្តបន្ទាយមានជ័យ  បានចូលរួមយ៉ាងសកម្មក្នុងពិធីបុណ្យជាតិ  និងព្រឹត្តិការណ៍នានារៀបចំដោយរដ្ឋបាលខេត្តបន្ទាយមានជ័យ និងមន្ទីរអប់រំ យុវជន និងកីឡាខេត្តបន្ទាយមានជ័យ។

### ២ ឈ្មោះនិងសម្រែកក្រុមភ្លេងកាយរឹទ្ធិ

- ឈ្មោះក្រុមភ្លេងកាយរឹទ្ធិខេត្តបន្ទាយមានជ័យ៖ "ក្រុមភ្លេងព្យុហយាត្រាកាយរឹទ្ធិខេត្តបន្ទាយមានជ័យ"។
- សម្រែកក្រុមភ្លេងកាយរឹទ្ធិ៖ ចាប់ផ្ដើមមេក្រុមស្រែកពាក្យ"កាយរឹទ្ធិ" សមាជិកស្រែកបន្ទរពាក្យ"បន្ទាយមានជ័យ ស្មារតីសន្តិភាព"។








## ក្រុមភ្លេងកាយរឹទ្ធិ ខេត្តព្រះសីហនុ

### ១ សាវតារ

ក្រុមភ្លេងកាយរឹទ្ធិខេត្តព្រះសីហនុ បានបង្កើតឡើងនៅខែមករា ឆ្នាំ២០២៦ ក្រោមការជួយឧបត្ថម្ភគាំទ្រពី ឯកឧត្តម **សាយ សំអាល់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគររូបនីយកម្មនិងសំណង់ និង ឯកឧត្តម **ម៉ាង ស៊ីណេត** អភិបាល នៃគណៈអភិបាលខេត្តព្រះសីហនុ។ ក្រុមភ្លេងនេះ មានសមាសភាពជាកាយរឹទ្ធិជំទង់ ៥៤នាក់ ស្រី ៣១នាក់ មកពីកងឯកភាពវិទ្យាល័យ ហ៊ុនសែន មិត្តភាព។ ក្រុមភ្លេងកាយរឹទ្ធិខេត្តព្រះសីហនុ បានចូលរួមយ៉ាងសកម្មក្នុងពិធីបុណ្យជាតិ និងព្រឹត្តិការណ៍នានា រៀបចំដោយរដ្ឋបាលខេត្តព្រះសីហនុ និងមន្ទីរអប់រំ យុវជន និងកីឡាខេត្តព្រះសីហនុ។

### ២ ឈ្មោះនិងសម្រែកក្រុមភ្លេងកាយរឹទ្ធិ

- ឈ្មោះក្រុមភ្លេងកាយរឹទ្ធិខេត្តព្រះសីហនុ៖ "ក្រុមភ្លេងព្យុហយាត្រាកាយរឹទ្ធិខេត្តព្រះសីហនុ"។
- សម្រែកក្រុមភ្លេងកាយរឹទ្ធិ៖ ចាប់ផ្ដើមមេក្រុមស្រែកពាក្យ"ព្រះសីហនុ" សមាជិកស្រែកបន្ទរពាក្យ"ទឹកដីនៃសន្តិភាព និងការអភិវឌ្ឍ"។ មេក្រុមស្រែកពាក្យ "ព្រះសីហនុ" សមាជិកស្រែកបន្ទរពាក្យ "មិត្តភាព និងសាមគ្គីភាព"។ មេក្រុមស្រែកពាក្យ "មិត្តភាព" សមាជិកស្រែកបន្ទរពាក្យ "មិត្តភាព ឈ្នះ ឈ្នះ ឈ្នះ។







## ក្រុមភ្លេងកាយរឹទ្ធិ ខេត្តរតនគិរី

### ១ សារតារ

ក្រុមភ្លេងកាយរឹទ្ធិខេត្តរតនគិរី បានបង្កើតឡើងនៅក្នុងឆ្នាំ២០១០ ក្រោមការជួយឧបត្ថម្ភគាំទ្រពីមន្ទីរអប់រំ យុវជន និងកីឡាខេត្តខេត្តរតនគិរី។ ក្រុមភ្លេងនេះ មានសមាសភាពជាកាយរឹទ្ធិជំទង់ និងកាយរឹទ្ធិប្អូនចំនួន ៨០នាក់ ស្រី ៣៤នាក់ មកពីកងឯកភាពវិទ្យាល័យសម្តេចឪសម្តេចម៉ែ វិទ្យាល័យគ្រូយើង វិទ្យាល័យកុលសម្ពន្ធ័ វិទ្យាល័យបរកែវ វិទ្យាល័យប៊ូថងអូរជុំ។ ក្រុមភ្លេងកាយរឹទ្ធិខេត្តខេត្តរតនគិរី បានចូលរួមយ៉ាងសកម្មក្នុងពិធីបុណ្យជាតិ និងព្រឹត្តិការណ៍នានា ដែលរៀបចំដោយរដ្ឋបាលខេត្តរតនគិរី និងមន្ទីរអប់រំ យុវជន និងកីឡាខេត្តរតនគិរី។

### ២ ឈ្មោះនិងសម្រែកក្រុមភ្លេងកាយរឹទ្ធិ

- ឈ្មោះក្រុមភ្លេងកាយរឹទ្ធិខេត្តរតនគិរី៖ "ក្រុមភ្លេងព្យុហយាត្រាកាយរឹទ្ធិខេត្តរតនគិរី"។
- សម្រែកក្រុមភ្លេងកាយរឹទ្ធិ៖ ចាប់ផ្តើមមេក្រុមស្រែកពាក្យ "អកភ្នំ" សមាជិកស្រែកបន្ទរពាក្យ "មុំបី "។ បន្ទាប់មកសមាជិកក្រុមស្រែកបន្ត "ដំរីវៀសាន គិរីជាទីអភិវឌ្ឍ"។








## ក្រុមភ្លេងកាយរឹទ្ធិ ខេត្តកំពង់ធំ

### ១ សារតារ

ក្រុមភ្លេងកាយរឹទ្ធិខេត្តកំពង់ធំ បានបង្កើតឡើងនៅថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២៥ ក្រោមការជួយឧបត្ថម្ភគាំទ្រពីឯកឧត្តម **នួន ផារ័ត្ន** អភិបាល នៃគណៈអភិបាលខេត្តកំពង់ធំ និងមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ធំ។ ក្រុមភ្លេងនេះ មានសមាសភាពជាកាយរឹទ្ធិជំទង់ ៤៧នាក់ ស្រី ២៦នាក់ មកពីមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ធំ។ ក្រុមភ្លេងកាយរឹទ្ធិខេត្តកំពង់ធំ បានចូលរួមយ៉ាងសកម្មក្នុងពិធីបុណ្យជាតិ និងព្រឹត្តិការណ៍នានា រៀបចំដោយរដ្ឋបាលខេត្តកំពង់ធំ និងមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ធំ។

### ២ ឈ្មោះនិងសម្រែកក្រុមភ្លេងកាយរឹទ្ធិ

- ឈ្មោះក្រុមភ្លេងកាយរឹទ្ធិខេត្តកំពង់ធំ៖ "ក្រុមភ្លេងព្យុហយាត្រាកាយរឹទ្ធិខេត្តកំពង់ធំ"។
- សម្រែកក្រុមភ្លេងកាយរឹទ្ធិ៖ ចាប់ផ្តើមមេក្រុមស្រែកពាក្យ "កំពង់ធំ" សមាជិកស្រែកបន្ទរពាក្យ "សម្រែកតោព្រៃគុក"។ បន្ទាប់មកមេក្រុមស្រែកពាក្យ "កំពង់ធំ" សមាជិកស្រែកបន្ទរពាក្យ "កំពង់ធំ ឈ្នះ ឈ្នះ ហ្កោរៗ"។








# ក្រុមភ្លេងកាយរឹទ្ធិ រាជធានីភ្នំពេញ

## ១ សារតារ

ក្រុមភ្លេងកាយរឹទ្ធិរាជធានីភ្នំពេញ នៃកងឯកភាពវិទ្យាល័យបាក់ទូក បង្កើតឡើងនៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១១ក្រោមការជួយឧបត្ថម្ភគាំទ្រពី ឯកឧត្តម**សាយ សំអាល់** ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគររូបនីយកម្មនិងសំណង់ និង ឯកឧត្តម **កែប ជុតិមា** អតីតអភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ។ ក្រុមភ្លេងកាយរឹទ្ធិនេះ មានសមាសភាពជាកាយរឹទ្ធិជំទង់ ៤៤នាក់ ស្រី ១៨នាក់។ ក្រុមភ្លេងកាយរឹទ្ធិខេត្តរាជធានីភ្នំពេញ បានចូលរួមក្នុងពិធីបុណ្យជាតិ និងព្រឹត្តិការណ៍នានា ដែលរៀបចំឡើងដោយរាជរដ្ឋាភិបាល រដ្ឋបាលរាជធានីភ្នំពេញ និងមន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ។

## ២ ឈ្មោះនិងសម្រែកក្រុមភ្លេងកាយរឹទ្ធិ

- ឈ្មោះក្រុមភ្លេងកាយរឹទ្ធិរាជធានីភ្នំពេញ៖ "ក្រុមភ្លេងព្យុហយាត្រាកាយរឹទ្ធិវិទ្យាល័យបាក់ទូក"។
- សម្រែកក្រុមភ្លេងកាយរឹទ្ធិ៖ ចាប់ផ្ដើមមេក្រុមស្រែកពាក្យ "We are BTMB" សមាជិកស្រែកបន្ទរពាក្យ "ក្រុងចតុមុខមង្គល"។








## ក្រុមភ្លេងកាយរឹទ្ធិ ខេត្តសៀមរាប

### ១ សាវតារ

ក្រុមភ្លេងកាយរឹទ្ធិខេត្តសៀមរាបបានបង្កើតឡើងនៅខែមេសា ឆ្នាំ២០០៩ ក្រោមការជួយឧបត្ថម្ភគាំទ្រពីសម្តេចវិបុលបញ្ញា **សុខ អាន** អតីតប្រធានកាយរឹទ្ធិជាតិកម្ពុជា និងឯកឧត្តម **ស៊ូ ភិរិន្ទ** អតីតអភិបាល នៃគណៈអភិបាលខេត្តសៀមរាប និងមន្ទីរអប់រំ យុវជន និងកីឡាខេត្តសៀមរាប។ ក្រុមភ្លេងកាយរឹទ្ធិនេះ មានសមាសភាពជាកាយរឹទ្ធិជំទង់ ៥១នាក់ ស្រី ៣០នាក់ មកពីកងឯកភាពវិទ្យាល័យ១០មករា១៩៧៩ វិទ្យាល័យហ៊ុនសែនវត្តស្វាយវិទ្យាល័យហ៊ុនសែនសៀមរាបនិងវិទ្យាល័យសម្តេចឪ។ ក្រុមភ្លេងកាយរឹទ្ធិខេត្តសៀមរាបបានចូលរួមយ៉ាងសកម្មក្នុងពិធីបុណ្យជាតិ និងព្រឹត្តិការណ៍នានាដែលរៀបចំដោយរដ្ឋបាលខេត្តសៀមរាប និងមន្ទីរអប់រំ យុវជន និងកីឡាខេត្តសៀមរាប។

### ២ ឈ្មោះនិងសម្រែកក្រុមភ្លេងកាយរឹទ្ធិ

- ឈ្មោះក្រុមភ្លេងកាយរឹទ្ធិខេត្តសៀមរាប៖ "គ្រុឌអង្គរវីរៈជ័យសៀមរាប"។
- សម្រែកក្រុមភ្លេងកាយរឹទ្ធិ៖ ចាប់ផ្តើមមេក្រុមស្រែកពាក្យ "សៀមរាបឈ្នះ ឈ្នះ" សមាជិកស្រែកបន្ទរពាក្យ "គ្រុឌអង្គរវីរៈជ័យសៀមរាប អស្ចារ្យៗ"។








## ក្រុមភ្លេងកាយរឹទ្ធិ ខេត្តកណ្ដាល

### ១ សាវតារ

ក្រុមភ្លេងកាយរឹទ្ធិខេត្តកណ្ដាល បង្កើតឡើងនៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨ ក្រោមការជួយឧបត្ថម្ភគាំទ្រពី សម្ដេចវិបុលបញ្ញា **សុខ អាន** អតីតប្រធានកាយរឹទ្ធិជាតិកម្ពុជា និងឯកឧត្តម **គន់ គីម** អតីតអភិបាលនៃគណៈអភិបាលខេត្តកណ្ដាល និងមន្ទីរអប់រំ យុវជន និងកីឡាខេត្តកណ្ដាល។ ក្រុមភ្លេងកាយរឹទ្ធិនេះ មានសមាសភាពជាកាយរឹទ្ធិជំទង់ ៧៥នាក់ ស្រី ៤០នាក់ មកពីកងឯកភាពមជ្ឈមណ្ឌលយុវជនខេត្តកណ្ដាល។ ក្រុមភ្លេងកាយរឹទ្ធិខេត្តកណ្ដាល បានចូលយ៉ាងសកម្មរួមក្នុងពិធីបុណ្យជាតិ និងព្រឹត្តិការណ៍នានា រៀបចំដោយរដ្ឋបាលខេត្តកណ្ដាល និងមន្ទីរអប់រំ យុវជន និងកីឡាខេត្តកណ្ដាល។

### ២ ឈ្មោះនិងសម្រែកក្រុមភ្លេងកាយរឹទ្ធិ

- ឈ្មោះក្រុមភ្លេងកាយរឹទ្ធិខេត្តកណ្ដាល៖ "ក្រុមភ្លេងព្យុហយាត្រាកាយរឹទ្ធិខេត្តកណ្ដាល"។
- សម្រែកក្រុមភ្លេងកាយរឹទ្ធិ៖ ចាប់ផ្ដើមមេក្រុមស្រែកពាក្យ "កាយរឹទ្ធិខេត្តកណ្ដាល" សមាជិកស្រែកបន្ទរពាក្យ "រឹងមាំ គាំទ្រសន្តិភាពនិងការអភិវឌ្ឍ"។








## ក្រុមភ្លេងកាយរឹទ្ធិ ខេត្តកោះកុង

### ១ សាវតារ

ក្រុមភ្លេងកាយរឹទ្ធិខេត្តកោះកុង បានបង្កើតឡើងនៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២០ ក្រោមការជួយឧបត្ថម្ភគាំទ្រពី លោកជំទាវ **មិថុនា ភូថង** អតីតអភិបាល នៃគណៈអភិបាលខេត្តកោះកុង លោកជំទាវ **ឈី វ៉ា** អភិបាល នៃគណៈអភិបាលខេត្តកោះកុង និងមន្ទីរអប់រំ យុវជន និងកីឡាខេត្តកោះកុង។ ក្រុមភ្លេងកាយរឹទ្ធិនេះមានសមាសភាពជាកាយរឹទ្ធិជំទង់និងកាយរឹទ្ធិប្អូនចំនួន៣០នាក់ស្រី១៧នាក់មកពីកងឯកភាពវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសតេជោសែនកោះកុង។ ក្រុមភ្លេងកាយរឹទ្ធិខេត្តកោះកុងបានចូលរួមយ៉ាងសកម្មក្នុងពិធីបុណ្យជាតិ និងព្រឹត្តិការណ៍នានា រៀបចំដោយរដ្ឋបាលខេត្តកោះកុង និងមន្ទីរអប់រំ យុវជន និងកីឡាខេត្តកោះកុង។

### ២ ឈ្មោះនិងសម្រែកក្រុមភ្លេងកាយរឹទ្ធិ

- ឈ្មោះក្រុមភ្លេងកាយរឹទ្ធិខេត្តកោះកុង៖ "ក្រុមភ្លេងកាយរឹទ្ធិវិទ្យាល័យ ច.ប. តេជោសែនកោះកុង"។
- សម្រែកក្រុមភ្លេងកាយរឹទ្ធិ៖ ចាប់ផ្ដើមមេក្រុមស្រែកពាក្យ "កោះកុងគិរីបរិព័ទ្ធសមុទ្រមេឃា" សមាជិកស្រែកបន្ទរពាក្យ "កាយរឹទ្ធិរស់ក្នុងសន្តិភាពនិងការអភិវឌ្ឍ"។











# ក្រុមភ្លេងកាយរឹទ្ធិ ខេត្តកំពង់ចាម

## ១ សារតារ

ក្រុមភ្លេងកាយរឹទ្ធិខេត្តកំពង់ចាម បានបង្កើតឡើងនៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០២៥ ក្រោមការជួយឧបត្ថម្ភគាំទ្រពី ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងជាប្រធានកាយរឹទ្ធិជាតិកម្ពុជា ឯកឧត្តម **អ៊ុន ចាន់ដា** អភិបាល នៃគណៈអភិបាលខេត្តកំពង់ចាម និងមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ចាម។ ក្រុមភ្លេងនេះ មានសមាសភាពជាកាយរឹទ្ធិជំទង់ ៣០នាក់ ស្រី ១០នាក់ មកពីកងឯកភាពវិទ្យាល័យ ហ៊ុនសែន ខ្ចៅ ស្រុកកងមាស ខេត្តកំពង់ចាម។ ក្រុមភ្លេងកាយរឹទ្ធិខេត្តកំពង់ចាម បានចូលរួមក្នុងពិធីបុណ្យជាតិ និងព្រឹត្តិការណ៍នានា ដែលរៀបចំដោយរដ្ឋបាលខេត្តកំពង់ចាម និងមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ចាម។

## ២ ឈ្មោះនិងសម្រែកក្រុមភ្លេងកាយរឹទ្ធិ

- ឈ្មោះក្រុមភ្លេងកាយរឹទ្ធិខេត្តកំពង់ចាម៖ "ក្រុមភ្លេងព្យុហយាត្រាកាយរឹទ្ធិខេត្តកំពង់ចាម"។
- សម្រែកក្រុមភ្លេងកាយរឹទ្ធិ៖ ចាប់ផ្ដើមមេក្រុមស្រែកពាក្យ "កំពង់ចាម" សមាជិកស្រែកបន្ទរពាក្យ "ស៊ូៗ"។ មេក្រុមស្រែកពាក្យ "កំពង់ចាម" សមាជិកស្រែកបន្ទរពាក្យ "ព្យាយាម"។ មេក្រុមស្រែកពាក្យ "កំពង់ចាម" សមាជិកស្រែកបន្ទរពាក្យ "ឈ្នះ ឈ្នះ ឈ្នះ"។









# របៀបវារៈនិងកម្មវិធី
# ការប្រកួតក្រុមភ្លេងកាយរឹទ្ធិថ្នាក់ជាតិលើកទី៣

ថ្ងៃអង្គារ ២កើត ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
ត្រូវនឹងថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៦ ពហុកីឡដ្ឋានជាតិអូឡាំពិក

០៦:៣០-០៧:០០ ជួបជុំកាយរឹទ្ធិ កាយឫទ្ធិនារី កាកបាទក្រហមកម្ពុជា ស.ស.យ.ក. សិស្សានុសិស្ស និងនិស្សិត
០៧:០០-០៧:៤៥ ការអញ្ជើញដល់របស់គណៈអធិបតី និងភ្ញៀវកិត្តិយស
០៧:៤៥-០៨:០០ ការអញ្ជើញដល់របស់ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
០៨:០០-១១:៣០ ដំណើរការកម្មវិធី

១-ការបង្ហាញក្បួនដំណើររបស់បេក្ខជនក្រុមភ្លេងកាយរឹទ្ធិ
២-ពិធីកាយរឹទ្ធិ និងគោរពវិញ្ញាណក្ខន្ធវីរកងទ័ពពលី
៣-សុន្ទរកថាស្វាគមន៍ និងរបាយការណ៍សកម្មភាពរបស់ លោក **ឯម ពិសិដ្ឋ** ប្រធាននាយកដ្ឋានសហប្រតិបត្តិការកាយរឹទ្ធិ
៤-ការសម្តែងលំហាត់របៀបកាយរឹទ្ធិនៃកងឯកភាពវិទ្យាល័យជាស៊ីមសាមគ្គី
៥-ប្រសាសន៍សំណេះសំណាលរបស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងជាប្រធានកាយរឹទ្ធិជាតិកម្ពុជា
៦-ដំណើរការប្រកួតក្រុមភ្លេងកាយរឹទ្ធិ ៥ក្រុម
៧-ទស្សនីយភាពតន្ត្រីកម្សាន្ត
៨-ពិធីប្រគល់លិខិតថ្លែងអំណរគុណដល់សប្បុរសជន
៩-ពិធីប្រកាសលទ្ធផល និងប្រគល់ពានរង្វាន់
១០-គោរពទង់ជាតិបិទកម្មវិធី។

(ចប់កម្មវិធី)

*គណៈកម្មការរៀបចំរក្សាសិទ្ធិកែប្រែកម្មវិធីក្នុងករណីចាំបាច់!*

ទំនាក់ទំនងព័ត៌មាន៖ 016 666 977 / 012 408180




# កាយរឹទ្ធិស្រឡាញ់




# និងការពារសន្តិភាព

Messengers of Peace

# ឆន្ទៈកាយរឹទ្ធិជាតិកម្ពុជា

I. ក្រោមម្លប់សន្តិភាព កាយរឹទ្ធិសច្ចា ពួកយើងជាអ្នកនាំ សារសន្តិភាព
សន្យាមិនរុញរា ពេញចិត្តនិងព្រមលះបង់ ដឹងគុណ ស្ថាបនិកសន្តិភាពថ្លៃថ្លា ។

II. ដំណើរឈានបន្តមហាបវរ បន្តបោះជំហាន ដើម្បីជាតិខេមរា
យើងរួបរួមជាកម្លាំង សាងល្អដើម្បីរដ្ឋា សន្យាលះបង់ដើម្បីកម្ពុជា អូ. ហូ.... ។

**~ ភ្លេង ~ បន្ទរ** (--)

III. ឆន្ទៈកាយរឹទ្ធិជាតិកម្ពុជា ស្មោះស្ម័គ្រពុះពារសាងអំពើល្អ
នាំសារសន្តិភាព តាំងចិត្តធ្វើរឿងល្អក្នុងជីវិត
ឆន្ទៈកាយរឹទ្ធិជាតិកម្ពុជា លះបង់ពុះពារមិនរាថយ
ដើម្បី ជាតិ សាសនា ព្រះមហាក្សត្រយើង កាយរឹទ្ធិសូមសន្យា អូ. ហូ.... ។

**~ ភ្លេង ~**

បន្ទរ. រួមគ្នាដើម្បីកម្ពុជា កាយរឹទ្ធិពុះពារ ដើរឆ្ពោះមិនរាថយ បេះដូងនេះដើម្បីកម្ពុជា
រក្សាសន្តិភាព បន្តពីអ្នកមានគុណ ពួកយើងសន្យា ត្រង់ត្រាប់ឆន្ទៈឧត្តម
យើងដើរតាមគន្លងអ្នកមានគុណយើងតទៅ អូ. ហូ....។

(**២ដង**)

**និពន្ធទំនុកច្រៀងដោយ៖ កញ្ញា ច័ន្ទ មល្លិកា**
**និពន្ធបទភ្លេងដោយ៖ លោក សាន សុវណ្ណឌីន**
**ច្រៀងដោយ៖ លោកស្រី ឌិក សុគន្ធកញ្ញា**
**ភ្នំពេញ,ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៥**

# អ្នកនាំសារសន្តិភាព

**I.** ផ្ដើមចេញពីពួកយើង ផ្ដើមពីបេះដូងបរិសុទ្ធ
ចិត្តយើងមោះមុត បណ្ដុះគ្រាប់ពូជសន្តិភាព មិនប្រកាន់ពណ៌សម្បុរ
មិនប្រកាន់ឋានៈខ្ពស់ទាប យើងរស់ក្រោមមេឃតែមួយក្នុងលោកិយនេះ។

**II.** កាន់ដៃគ្នាឱ្យជាប់ ភ្ជាប់ចិត្តរួមគ្នាសាមគ្គី ពីកម្ពុជាទៅពិភពលោក
ផ្សព្វផ្សាយរឿងដែលល្អៗ បន្តឱ្យល្បីកក្រើក ថ្ងៃនេះថ្ងៃស្អែកកម្ពុជាមានស្នាមញញឹម។

**R.** យើងជាអ្នកនាំសារ សារសន្តិភាព យើងរស់ក្រោមមេឃ
ក្រោមមេឃមានក្ដីមេត្តា ផ្ដើមចេញពីខ្ញុំ ផ្ដើមចេញពីអ្នក
បេះដូងបរិសុទ្ធស្នេហា ពេញចិត្តរួមគ្នានាំសារ ប្រាប់ពិភពលោកថា
សន្តិភាពទើបជាពន្លឺចិត្ត។

**III.** ផ្ដើមចេញពីពួកយើង រួមគ្នាសាងអំពើល្អ មានឆន្ទៈដាច់ខាតមិនរាថយឡើយ
សាងល្អរួមគ្នារួមចិត្ត កាយរឹទ្ធិមិត្តយើងអើយ គឺយើងនេះហើយអ្នកនាំសារសន្តិភាព!

(បន្ទរ) សន្តិភាព! សន្តិភាព! សន្តិភាព! ហា!ហា!

**I – II – R – R**

(បន្ទរ) សន្តិភាព! សន្តិភាព! សន្តិភាព! ហា!ហា!

**និពន្ធទំនុកច្រៀងដោយ៖ កញ្ញា ច័ន្ទ មល្លិកា**
**និពន្ធបទភ្លេងដោយ៖ លោក សាន សុវណ្ណឌីន**
**ច្រៀងដោយ៖ លោកស្រី ឱក សុគន្ធកញ្ញា**



# កាយរឹទ្ធិបម្រើ និងសង្គ្រោះមនុស្សជាតិ គ្រប់កាលៈទេសៈ